ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
**លេខាធិការដ្ឋាន**

លេខ...៤០៣...ស.ក..../គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១១

**សូមជម្រាបជូន**

**ឯកឧត្តមអភិបាល និងជាប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី ខេត្ត**

**កម្មវត្ថុ:** ស្តីពីការវាយតម្លៃការបំពេញការងាររយៈពេលសាកល្បងរបស់ទីប្រឹក្សាថ្នាក់ក្រោមជាតិ ក្រោមក្របខណ្ឌនៃផែនការអនុវត្តរយៈពេល០៣ឆ្នាំ (២០១១-២០១៣) ។

**យោង:** កិច្ចសន្យាការងាររបស់ទីប្រឹក្សា

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមជ្រាបថា ផ្អែកតាមការណែនាំដែលមានចែងនៅក្នុងសៀវភៅណែនាំស្តីពីនីតិវិធីរដ្ឋបាលរបស់គ.ជ.អ.ប និងលក្ខខណ្ឌនៃកិច្ចសន្យាការងាររបស់ទីប្រឹក្សាម្នាក់ៗ ការវាយតម្លៃការបំពេញការងារនឹងត្រូវធ្វើឡើងនៅមុនពេលបញ្ចប់រយៈពេលសាកល្បង ឬមុនពេលបន្តកិច្ចសន្យាសម្រាប់ឆ្នាំបន្ទាប់ ។

ក្នុងន័យនេះ លេខាធិការដ្ឋាន គ.ជ.អ.ប សូមធ្វើការណែនាំដល់គណៈកម្មាធិការប្រតិបត្តិរាជធានី ខេត្ត រៀបចំដំណើរការវាយតម្លៃទីប្រឹក្សារបស់ខ្លួនទាំងឡាយណាដែលស្ថិតក្នុងកិច្ចសន្យាសាកល្បងការងាររយៈពេល៣ខែដំបូង ដែលក្នុងនេះរួមមាន: ទីប្រឹក្សាថ្នាក់រាជធានី ខេត្តមួយចំនួន និងទីប្រឹក្សាថ្នាក់ក្រុង ស្រុក ខណ្ឌទាំងអស់ដោយអនុលោមតាមនីតិវិធីដូចខាងក្រោម :

## ១. ការបង្កើតគណៈកម្មការវាយតម្លៃ

រាជធានី ខេត្តនីមួយៗ ត្រូវរៀបចំគណៈកម្មការវាយតម្លៃដោយរួមមានសមាសភាពដូចខាងក្រោម :

១. គណៈកម្មការវាយតម្លៃទីប្រឹក្សាថ្នាក់រាជធានី ខេត្ត

- អភិបាល ឬអភិបាលរងរាជធានី ខេត្ត ០១រូប — ជាប្រធាន
- នាយក ឬនាយករងរដ្ឋបាល ឬសមាជិកអចិន្ត្រៃយ៍នៃគ.ប្រ ០១រូប — សមាជិក
- ប្រធាន ឬអនុប្រធានផ្នែករដ្ឋបាលនិងគ្រប់គ្រងកិច្ចសន្យានៃគ.ប្រ ០១រូប — សមាជិក
- ប្រធាន ឬអនុប្រធានផ្នែកនៃគ.ប្រដែលពាក់ព័ន្ធ ០១រូប — សមាជិក
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត ០១រូប — សមាជិក

**សំគាល់:**

ក្នុងករណីវាយតម្លៃទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត ទីប្រឹក្សាថ្នាក់រាជធានី ខេត្តទាំងអស់អាចធ្វើការជ្រើសរើសតំណាងរបស់ខ្លួន០១រូប ដើម្បីចូលរួមជាសមាជិកគណៈកម្មការ ។

២. គណៈកម្មការវាយតម្លៃទីប្រឹក្សាថ្នាក់ក្រុង ស្រុក ខណ្ឌ

- អភិបាល ឬអភិបាលរងរាជធានី ខេត្ត ០១រូប ជាប្រធាន
- នាយក ឬនាយករងរដ្ឋបាល ឬសមាជិកអចិន្ត្រៃយ៍នៃគ.ប្រ ០១រូប សមាជិក
- អភិបាល ឬអភិបាលរងក្រុង ស្រុក ខណ្ឌសាមី ០១រូប សមាជិក
- នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌសាមី ០១រូប សមាជិក
- ទីប្រឹក្សាគ្រប់គ្រងកម្មវិធីជាតិថ្នាក់រាជធានី ខេត្ត ឬតំណាង ០១រូប សមាជិក

គណៈកម្មការវាយតម្លៃមានតួនាទី និងភារៈកិច្ចដូចខាងក្រោម :

- ពិនិត្យឡើងវិញនូវការបំពេញភារៈកិច្ចរបស់ទីប្រឹក្សាដោយផ្អែកតាមលក្ខខណ្ឌការងារ និងសមិទ្ធិផលដែលសំរេចបានជាក់ស្តែង ។
- ផ្តល់អនុសាសន៍លើចំណុចសំខាន់ៗសំរាប់កែលម្អការងារទៅអនាគត និងលទ្ធភាពនៃការបន្តកិច្ចសន្យាការងាររបស់ទីប្រឹក្សារហូតដល់បំណាច់ឆ្នាំ២០១១ ។
- ធ្វើរបាយការណ៍អំពីលទ្ធផលនៃការវាយតម្លៃ និងផ្ញើជូន គ.ជ.អ.ប

## ២. ដំណើរការវាយតម្លៃ

ខាងក្រោមនេះ គឺជាការណែនាំក្នុងការបំពេញទម្រង់វាយតម្លៃៈ

### ២.១ ផ្នែកទី១: ព័ត៌មានគោល

ផ្នែកនេះត្រូវបំពេញដោយទីប្រឹក្សាដែលនឹងត្រូវវាយតម្លៃ ហើយទម្រង់នេះមានសេចក្តីពន្យល់លម្អិតរួចជាស្រេច ។

### ២.២ ផ្នែកទី២: ផែនការការងារ

ផ្នែកនេះនឹងត្រូវបំពេញដោយទីប្រឹក្សាដែលនឹងត្រូវវាយតម្លៃ ដោយផ្អែកលើការពណ៌នាភារៈកិច្ចនិងមុខងារព្រមទាំងភារៈកិច្ចបន្ថែមទៀតដែលបានកំណត់ ។ អ្វីដែលសំខាន់សម្រាប់ផ្នែកនេះ គឺការពិពណ៌នាដោយមានសូចនាករច្បាស់លាស់អំពីលទ្ធផលគ្រោងទុកក្នុងកិច្ចសន្យាដែលនឹងត្រូវអនុវត្តដោយទីប្រឹក្សាម្នាក់ៗ ។

### ២.៣ ផ្នែកទី៣: ការវាយតម្លៃខ្លួនឯង

ផ្នែកនេះត្រូវបំពេញដោយទីប្រឹក្សារៀងៗខ្លួន នៅមុនពេលបញ្ចប់កិច្ចសន្យាដោយផ្អែកលើសមិទ្ធិផលការងារជាក់ស្តែងដោយធៀបនឹងលទ្ធផលគ្រោងទុកនៅក្នុងផ្នែកទី២ និងដោយបញ្ជាក់ពីសូចនាករដែលពាក់ព័ន្ធ ។ គួររាប់បញ្ចូលសមិទ្ធិផលការងារសំខាន់ផ្សេងៗផងដែរ ទោះជាសមិទ្ធិផលទាំងនោះមិនមាននៅក្នុងលទ្ធផលគ្រោងទុកក្នុងផ្នែកទី២ក៏ដោយ ។

### ២.៤ ផ្នែកទី៤: ការវាយតម្លៃដោយដាក់ពិន្ទុរបស់គណៈកម្មការ

បន្ទាប់ពីទទួលបានទម្រង់វាយតម្លៃខ្លួនឯងពីទីប្រឹក្សារួចមក គណៈកម្មការត្រូវធ្វើការវាយតម្លៃដោយដាក់ពិន្ទុដោយផ្អែកលើផ្នែកសំខាន់ៗចំនួន០៩ ដូចជាៈ

១. ភាពច្នៃប្រឌិត
២. គុណភាពការងារ
៣. ទំនាក់ទំនងជាមួយអ្នកចូលរួមការងារ
៦. ចំណេះដឹងពីនីតិវិធីចាំបាច់ផ្សេងៗ
៧. សមត្ថភាពធ្វើការជាក្រុម
៨. សមត្ថភាពទំនាក់ទំនង

៤. គំនិតផ្តួចផ្តើម

៥. សមត្ថភាពជំនាញ

៨. ការបង្កើតការរួមចំណែក និងបណ្តាញ

ការវាយតម្លៃនេះ ត្រូវធ្វើឡើងតាមរយៈការប្រជុំពិភាក្សារវាងសមាជិកគណៈកម្មការទាំងអស់ដែលបានរៀបរាប់ខាងលើ ។ ពិន្ទុសរុបចុងក្រោយនិងអនុសាសន៍នៃលទ្ធភាពបន្ត ឬមិនបន្តកិច្ចសន្យា គឺបានមកពីការពិភាក្សាព្រមព្រៀងរវាងសមាជិកទាំងអស់នៃគណៈកម្មការវាយតម្លៃ ។

## ២.៥ ផ្នែកទី៥: យោបល់របស់ទីប្រឹក្សា

ទីប្រឹក្សាអាចមានយោបល់ឬសំណូមពរផ្សេងៗដែលទាក់ទងនឹងការបំពេញការងាររបស់ខ្លួន ក៏ដូចជាទស្សនៈនានាដែលអាចរួមចំណែកធ្វើអោយការអនុវត្តន៍កម្មវិធីមានការប្រសើរឡើងក្នុងពេលអនាគត ។

## ២.៦ ផ្នែកទី៦: ការសម្រេចចុងក្រោយរបស់គណៈកម្មការ និងការរៀបចំរបាយការណ៍

ក្រោយពីបញ្ចប់ការវាយតម្លៃ គណៈកម្មការត្រូវរៀបចំរបាយការណ៍លទ្ធផល ដោយបញ្ជាក់ច្បាស់លាស់អំពីពិន្ទុតាមផ្នែកនីមួយៗ ពិន្ទុសរុប ចំណុចត្រូវកែលម្អ និងអនុសាសន៍ ដែលពាក់ព័ន្ធដល់លទ្ធភាពនៃការបន្តកិច្ចសន្យាការងាររបស់ទីប្រឹក្សាម្នាក់ៗរហូតដល់បំណាច់ឆ្នាំ២០១១ ។ គណៈកម្មការក៏អាចផ្តល់មតិត្រលប់ដល់ទីប្រឹក្សាវិញអំពីលទ្ធផលនៃការសំរេចចុងក្រោយ និងអនុសាសន៍នានារបស់គណៈកម្មការ ។ របាយការណ៍សរុបចុងក្រោយត្រូវបញ្ជូនមកផ្នែករដ្ឋបាលនៃអង្គភាពគាំទ្រកម្មវិធី**យ៉ាងយូរបំផុតរយៈពេល០១សប្តាហ៍មុននឹងកិច្ចសន្យាសាកល្បងការងារត្រូវបានបញ្ចប់** ដើម្បីផ្នែករដ្ឋបាលមានលទ្ធភាពបូកសរុប និងដាក់ជូនថ្នាក់ដឹកនាំនៃលេខាធិការដ្ឋាន គ.ជ.អ.ប ដើម្បីពិនិត្យ និងសម្រេច ។

**<u>បញ្ជាក់:</u>** ១. ការវាយតម្លៃទីប្រឹក្សាថ្នាក់រាជធានី ខេត្ត នឹងត្រូវធ្វើឡើងតែចំពោះរាជធានី ខេត្តមួយចំនួនដែលមានទីប្រឹក្សាកំពុងបំពេញការងារក្នុងរយៈពេលសាកល្បងប៉ុណ្ណោះ ។

២. ការវាយតម្លៃទីប្រឹក្សាថ្នាក់ក្រុង ស្រុក ខណ្ឌ នឹងត្រូវធ្វើឡើងទូទាំង២៤ រាជធានី ខេត្ត ដោយទីប្រឹក្សាទាំងនេះស្ថិតក្នុងរយៈពេលសាកល្បងការងារ ។

អាស្រ័យហេតុនេះ សូមឯកឧត្តមចាត់ចែងអនុវត្តការងារនេះប្រកបដោយប្រសិទ្ធិភាពខ្ពស់ ។

សូមជូនភ្ជាប់មកជាមួយនូវទម្រង់បែបបទវាយតម្លៃ និងបញ្ជីរាយនាមទីប្រឹក្សាដែលត្រូវធ្វើការវាយតម្លៃ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**អនុប្រធាន**

**ចាន់_ចំរើន**